THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១

ជូនចំពោះក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៖

នៅថ្ងៃអង្គារ ទី៣១ ខែសីហា យើងនឹងចាប់ផ្តើមឆ្នាំសិក្សា ២០២១-២២ ដោយរៀនក្នុងថ្នាក់ផ្ទាល់ ចំនួន ៥ ថ្ងៃក្នុងមួយសប្តាហ៍។ យើងបានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយសហការីរបស់យើងនៅ ក្រសួងសាធារណៈសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យា (PDPH) និងមន្ទីរពេទ្យកុមារនៃទីក្រុងហ្វីឡាដែលហ្វ្យា (CHOP) ដើម្បីតាមដានស្ថានភាពជំងឺ ខូវីដ-១៩ និងចាត់វិធានការសុខភាព និងសុវត្ថិភាពបន្ថែម ដែលយើងអាចអនុវត្តដើម្បីការពារសុខភាព និងសុខុមាលភាព ដល់អ្នកគ្រប់គ្នានៅក្នុងសាលា និងការិយាល័យរបស់យើង។ ខ្ញុំសរសេរលិខិតនេះទៅជម្រាបលោកអ្នកអំពីព័ត៌មានសំខាន់ថ្មីពីរ។

**<u>ការតម្រូវឱ្យចាក់ថ្នាំបង្ការរោគ ខូវីដ-១៩</u>**
កាលពីយប់មិញ ក្រុមប្រឹក្សាធិការអប់រំបានបោះឆ្នោតតម្រូវឱ្យបុគ្គលិកទាំងអស់ចាក់ថ្នាំបង្ការរោគ ខូវីដ-១៩។ ខ្ញុំគាំទ្រយ៉ាងពេញទំហឹងចំពោះការសម្រេចចិត្តនេះ ពីព្រោះវិទ្យាសាស្ត្រច្បាស់លាស់ណាស់៖ ថ្នាំបង្ការរោគ ខូវីដ-១៩ មានប្រសិទ្ធភាព។ ការសិក្សាថ្មីដោយ មន្ទីរពេទ្យកុមារនៃទីក្រុងហ្វីឡាដែលហ្វ្យា (CHOP) ប្រើទិន្នន័យពីសាលារបស់យើងផ្ទាល់ គឺជាភស្តុតាងបន្ថែមថា ថ្នាំបង្ការរោគពិតជាមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារការរាលដាលនៃជំងឺ ខូវីដ-១៩។

យើងកំពុងធ្វើការស្វែងយល់ព័ត៌មានលម្អិតចុងក្រោយ ហើយនឹងផ្តល់ព័ត៌មានបន្ថែមនៅពេលយើងមាន។

**<u>គំរូធ្វើតេស្ត ខូវីដ-១៩ ថ្មី ដើម្បីនៅក្នុងសាលា</u>**
តាមការណែនាំថ្មីពី ក្រសួងសាធារណៈសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យា យើងឈប់ធ្វើតាមគំរូធ្វើតេស្តដើម្បីនៅក្នុងសាលាទៀតហើយ។ បើអ្នកណាម្នាក់ត្រូវបានគេកំណត់ថាបាននៅជិតអ្នកដែលធ្វើតេស្តវិជ្ជមានជំងឺ ខូវីដ-១៩ នឹងត្រូវដាក់ឱ្យនៅដាច់ពីគេរយៈពេល ១០ ថ្ងៃ។

ព័ត៌មានថ្មីអំពីសុខភាព និងសុវត្ថិភាពទាំងនេះ គឺជាការបន្ថែមលើស្រទាប់សុវត្ថិភាពជាច្រើនទៀតដែលយើងនឹងមាននៅគ្រប់សាលា រួមទាំងការធ្វើតេស្តបុគ្គលិកប្រចាំសប្តាហ៍ ការផ្តល់ការធ្វើតេស្តដល់សិស្សដែលមានអាការៈរោគដូចជាខូវីដ ពេលនៅសាលា និងតម្រូវឱ្យមនុស្សគ្រប់រូបនៅក្នុងសាលារបស់យើងពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការរោគ។ ដើម្បីស្វែងយល់បន្ថែម សូមធ្វើយ៉ាងណាត្រូវមើល ពិធីការសុខភាព និងសុវត្ថិភាពថ្មី (updated health and safety protocols) របស់យើង សូមមើល វីដេអូអំពីអ្វីដែលយើងកំពុងធ្វើដើម្បីគាំទ្រសុខភាព និងសុវត្ថិភាព សម្រាប់ការសិក្សាក្នុងថ្នាក់ផ្ទាល់ (We're Doing to Support Healthy & Safe In-

Person Learning Video) ហើយមើលបន្ទុកព័ត៌មានអំពីការវិលត្រឡប់មករៀនវិញរបស់យើង នៅ www.philasd.org/ringthebell។

យើងមានក្តីរំភើប និងត្រៀមខ្លួនជាស្រេចដើម្បីស្វាគមន៍ក្មេងៗត្រឡប់មករៀនវិញដោយសុវត្ថិភាព! ខ្ញុំសូមអញ្ជើញលោកអ្នកមកមើល Back-to-School Bus Tour របស់យើង ដើម្បីទទួលបានព័ត៌មាន សេវាកម្ម និង សំពៀតដាក់សៀវភៅជាមួយសំភារៈសិក្សា ដោយឥតគិតថ្លៃ ដើម្បីឱ្យលោកអ្នកអាចត្រៀមខ្លួនដើម្បីចុចកណ្តឹង នៅឆ្នាំសិក្សាថ្មី។

ដោយក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា